ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
លេខ : ៤១៧/១៥

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារគ្រប់គ្រងការងារព័ត៌មានវិទ្យា និងបណ្តាញព័ត៌មានសង្គម

## រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមស្មារតីអង្គប្រជុំ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ កំណត់ឱ្យមានការរៀបចំក្រុមការងារគ្រប់គ្រងការងារព័ត៌មានវិទ្យា និងបណ្តាញព័ត៌មានសង្គម។

## សម្រេច

**ប្រការ ១៖**

ត្រូវបានបង្កើត **ក្រុមការងារគ្រប់គ្រងការងារព័ត៌មានវិទ្យា និងបណ្តាញព័ត៌មានសង្គម** នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ឡុង ប៉ុណ្ណាសិរីវ័ឌ្ឍ** | អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធាន |
| ២- លោក | **ថឹង ពេញឫទ្ធ** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣-លោកស្រី | **ជា ណារិន** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៤- លោក | **ម៉ូង ច័ន្ទវាសនា** | ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ | សមាជិក |
| ៥- លោក | **ច័ន្ទ វណ្ណា** | ប្រធាននាយកដ្ឋានសម្ភារៈនិងបរិក្ខា | សមាជិក |
| ៦- លោក | **ម៉ាន់ វីរៈ** | ប្រធាននាយកដ្ឋានគណនេយ្យ | សមាជិក |

ក្រុមការងារនេះមានភារកិច្ច ៖

- ដឹកនាំ គ្រប់គ្រង និងចាត់ចែង ការងារប្រព័ន្ធព័ត៌មានវិទ្យារបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- គ្រប់គ្រង និងរៀបចំព័ត៌មានដើម្បីផ្សព្វផ្សាយលើគេហទំព័រ និងបណ្តាញព័ត៌មានសង្គមរបស់ក្រសួង
- ជម្រុញការរៀបចំផែនការការងារ និងផែនការយុទ្ធសាស្ត្រថវិកាលើការងារព័ត៌មានវិទ្យា ដើម្បីធានាការអភិវឌ្ឍចំណេះដឹងក្នុងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យានៅក្នុងក្រសួងឱ្យមានប្រសិទ្ធភាពខ្ពស់
- គ្រប់គ្រង និងចាត់ចែងលើការផ្តល់ឧបករណ៍ និងសេវាកម្មព័ត៌មានវិទ្យា ដើម្បីធានាការប្រើប្រាស់ឱ្យអស់សមត្ថភាព និងសមស្របតាមបទដ្ឋានបច្ចេកទេស
- សហការជាមួយក្រុមការងារព័ត៌មាន និងប្រតិកម្មរហ័សក្រសួង និងក្រុមអ្នកនាំពាក្យក្រសួង ដើម្បីធ្វើការតាមដាន ត្រួតពិនិត្យ និងវិភាគរាល់ព័ត៌មានដែលពាក់ព័ន្ធនិងវិស័យវប្បធម៌នៅលើបណ្តាញព័ត៌មានសង្គមនានា ដើម្បីចងក្រងជាសំណុំព័ត៌មានជូនថ្នាក់ដឹកនាំ
- រៀបចំប្រជុំ ឬសិក្ខាសាលា ស្តីពីការវិវឌ្ឍន៍ថ្មីនៃបច្ចេកវិទ្យា ដែលអាចមានបញ្ហាប្រឈមជាមួយនិងការងារ ឬទាក់ទងនិងបច្ចេកវិទ្យាព័ត៌មានដែលផ្តល់ផលប៉ះពាល់ដល់វិស័យវប្បធម៌
- ធ្វើរបាយការណ៍ ស្តីពីលទ្ធផលការងារ ជូន លោកជំទាវរដ្ឋមន្ត្រី
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ២ ៖**

ត្រូវបានបង្កើត**ក្រុមជំនួយការបច្ចេកទេស** ជំនួយការឱ្យក្រុមការងារគ្រប់គ្រងការងារព័ត៌មានវិទ្យា និងបណ្តាញព័ត៌មានសង្គម នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១- លោក | **ទឹម** | **ពេញឬទ្ធ** | អគ្គនាយករងរដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធាន |
| ២- លោក | **យស់** | **ខៀន** | អគ្គនាយករងបច្ចេកទេសវប្បធម៌ | អនុប្រធាន |
| ៣- លោក | **ហេង** | **សុផាឌី** | អគ្គនាយករងបេតិកភណ្ឌ | អនុប្រធាន |
| ៤- លោក | **កុក** | **រស់** | ប្រធាននាយកដ្ឋាននីតិកម្ម | សមាជិក |
| ៥- លោក | **សែន** | **កុសល** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦- លោក | **ស៊ីយ៉ុន** | **សុភារិទ្ធ** | ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសរុប | សមាជិក |
| ៧- លោក | **ត្រឹងឡុង** | **បូរិន** | ជំនួយការអមក្រសួង | សមាជិក |
| ៨- លោក | **ថាង** | **ច័ន្ទវិចិត្រ** | ប្រធានការិ.ព័ត៌មានវិទ្យា | សមាជិកអចិន្ត្រៃយ៍ |
| ៩- លោក | **យ៉ា** | **ដា** | នាយករងមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌ | សមាជិក |
| ១០- លោក | **ខៀវ** | **សំណាង** | | សមាជិក |

ក្រុមជំនួយការនេះមានភារកិច្ចដូចខាងក្រោម ៖

- គ្រប់គ្រងការអនុវត្តការងារព័ត៌មានវិទ្យារបស់ក្រសួង
- ពិនិត្យនិងរៀបចំអត្ថបទព័ត៌មានដើម្បីផ្សព្វផ្សាយលើគេហទំព័រ និងបណ្តាញព័ត៌មានសង្គមរបស់ក្រសួង
- រៀបចំ និងលើកគម្រោងស្នើសុំថវិកា ដើម្បីធានានូវកិច្ចដំណើរការ **ក្រុមការងារគ្រប់គ្រងការងារព័ត៌មានវិទ្យា និងបណ្តាញព័ត៌មានសង្គម** នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- សហការជាមួយអង្គភាពដែលពាក់ព័ន្ធ និងការិយាល័យព័ត៌មានវិទ្យា រៀបចំផែនការការងារ និងផែនការថវិកាសម្រាប់បំរើដល់ការងារព័ត៌មានវិទ្យាក្នុងការអភិវឌ្ឍចំណេះដឹង និងការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងក្រសួងឱ្យមានប្រសិទ្ធភាពខ្ពស់

- រៀបចំនិងតម្លើងឧបករណ៍ព័ត៌មានវិទ្យា និងប្រព័ន្ធបណ្តាញការងារ(Networks System) ផ្សេងៗ ជូនមន្ត្រីរាជការ និងផ្តល់ការណែនាំក្នុងប្រើប្រាស់ឱ្យអស់សមត្ថភាព ព្រមទាំងសមស្របតាមបទដ្ឋានបច្ចេកទេស
- ផ្តល់សេវាកម្មថែទាំ និងជួសជុលលើឧបករណ៍ព័ត៌មានវិទ្យា និងប្រព័ន្ធបណ្តាញការងារ(Network System) របស់ក្រសួង
- វាយតម្លៃគុណភាពឧបករណ៍ព័ត៌មានវិទ្យា និងសម្ភារៈអេឡិចត្រូនិចដែលពាក់ព័ន្ធ ដើម្បីរៀបចំបញ្ជីសៀវភៅបន្ទុកនៃឧបរណ៍ព័ត៌មានវិទ្យាក្រសួង
- រៀបចំធ្វើផែនការវិលស់ការប្រើប្រាស់ឧបករណ៍ព័ត៌មានវិទ្យា និងសម្ភារៈអេឡិចត្រូនិចដែលពាក់ព័ន្ធ ដើម្បីធានានូវសុវត្ថិភាព និងនិរន្តរភាព
- សហការជាមួយក្រុមការងារនិងអង្គភាពពាក់ព័ន្ធនានា ដើម្បីប្រមូលទិន្នន័យ និងព័ត៌មានផ្សេងៗ សម្រាប់ការងារចងក្រងសំណុំឯកសារ ឬព័ត៌មាន ជូនថ្នាក់ដឹកនាំក្រសួង
- រៀបចំការប្រជុំ ឬសិក្ខាសាលាផ្សេងៗបង្ហាញអំពីការវិវត្តន៍ថ្មីៗនៃបច្ចេកវិទ្យា ដែលអាចប្រឈមជាមួយនិងការងារ ឬបច្ចេកវិទ្យាព័ត៌មានទំនើបដែលផ្តល់ផលប៉ះពាល់ដល់ការងារ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រធានក្រុមការងារគ្រប់គ្រងការងារព័ត៌មានវិទ្យា និងបណ្តាញព័ត៌មានសង្គម
- ទទួលភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

**ប្រការ ៣ ៖**

ក្រុមការងារគ្រប់គ្រងការងារព័ត៌មានវិទ្យា និងបណ្តាញព័ត៌មានសង្គម នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ មានសិទ្ធិប្រើប្រាស់មន្ត្រីរាជការក្រោមឱវាទឱ្យជួយការងារបានតាមការចាំបាច់។

**ប្រការ ៤ ៖**

រាល់សេចក្តីសម្រេចទាំងឡាយណាដែលមានចែងខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះទុកជានិរាករណ៍។

**ប្រការ ៥ ៖**

នាយកខុទ្ទកាល័យ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ អគ្គនាយកបេតិកភណ្ឌ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ នាយិកាសាលាមធ្យមវិចិត្រសិល្បៈ គ្រប់អង្គភាពក្រោមឱវាទក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

ភឿង - សកុណា

**ចម្លងជូន ៖**
- ខុទ្ទកាល័យលោកជំទាវរដ្ឋមន្ត្រី
- គ្រប់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ
  *"ដើម្បីជូនជ្រាប"*
- ដូចមានក្នុងប្រការ១ និង ប្រការ២
  *"ដើម្បីអនុវត្ត"*
- ឯកសារ-កាលប្បវត្តិ